ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង ៖ ០៣៨/២០ - ផេក ធីក (ខេមបូឌា)**
**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **លីវ សុវណ្ណា**
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ផេក ធីក (ខេមបូឌា) ខូអិលធីឌី**
អាសយដ្ឋាន ៖ ភូមិគ្រួស សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប
ទូរស័ព្ទ ៖ ០៦៩ ២៣០ ៧៧៧ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជកចូលរួមសវនាការ៖

| | |
|---|---|
| ១- លោក AMBANPITIYA ARACHCHIGE CHAMARA CHATHURANGA | ប្រធានគ្រប់គ្រងប្រតិបត្តិការ |
| ២- លោកស្រី ជឹម ថារី | ប្រធានធនធានមនុស្ស |
| ៣- កញ្ញា Sandra D'Amico | Managing Director HRINC |
| ៤- លោក អេង រ៉ាឌី | មន្ត្រីផ្នែកច្បាប់ |
| ៥- លោកស្រី ខ្លឹម សុផាណារី | Managing Partner HRINC |
| ៦- លោកស្រី ជឹម ច័ន្ទរស្មី | មន្ត្រីអនុវត្តច្បាប់ |
| ៧- លោក សយ ផារិទ្ធិ | មន្ត្រីច្បាប់ GMAC |

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃ ក្រុមហ៊ុន ផេក ធីក (ខេមបូឌា) ខូអិលធីឌី**
អាសយដ្ឋាន ៖ ភូមិគ្រួស សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប
ទូរស័ព្ទ ៖ ០៧០ ៤៨ ៦៩ ០៨ ទូរសារ ៖ គ្មាន

តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ៖

១- លោក ឈេន សំបូរ មេធាវី

២- លោក ទូច កុសល ប្រធានសហព័ន្ធសហជីពCTWUF

៣- លោក ហ៊ាង វណ្ណារ៉ា អគ្គលេខាធិការសហព័ន្ធសហជីពCTWUF

៤- លោក ម៉េត រ៉ាត់ ប្រធានសហជីពមូលដ្ឋាន

៥- កញ្ញា គឿន ស្រីនិច អនុប្រធានសហជីពមូលដ្ឋាន

៦- លោក រីង វ៉ង់ អគ្គលេខាធិការសហជីពមូលដ្ឋាន

៧- កញ្ញា សោម គឹមហុង សកម្មជនសហជីព

៨- លោកស្រី ចាន់ វន្នី សមាជិកសហជីព

៩- លោកស្រី យ៉ាន វណ្ណា សមាជិកសហជីព

## បញ្ហាវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- **ចំណុចទី១**

**-ភាគីតំណាងកម្មករនិយោជិត** ទាមទារអោយនិយោជកសងប្រាក់រំលឹកអតីតភាពការងារមុនឆ្នាំ២០១៩ ដល់កម្មករនិយោជិតតាមច្បាប់។

**-ភាគីខាងនិយោជក** ក្រុមហ៊ុនបានអនុវត្តតាមសេចក្ដីណែនាំលេខ ០៤២/១៩ កប/សណនខល ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ ស្ដីពីការបើកប្រាក់រំលឹកអតីតភាពការងារដែលមានមុនឆ្នាំ២០១៩ សម្រាប់សហគ្រាសគ្រឹះស្ថានក្រៅពីផ្នែកវាយនភ័ណ្ឌកាត់ដេរ និងផលិតស្បែកជើង ត្រូវពន្យាពេលក្នុងការអនុវត្តទៅខែធ្នូ ឆ្នាំ២០២១ ដោយត្រូវទូទាត់រំលឹកចំនួន ៦ថ្ងៃ ក្នុងមួយឆ្នាំ។

២- **ចំណុចទី២**

**-ភាគីតំណាងកម្មករនិយោជិត** ទាមទារអោយនិយោជកសងប្រាក់ឈ្នួលពេញ ដល់កម្មករនិយោជិតដែលនិយោជកព្យួរកិច្ចសន្យាការងារខុសនិតិវិធីច្បាប់។

**-ភាគីខាងនិយោជក** ក្រុមហ៊ុនបានអនុវត្តតាមនិតិវិធីនៃការព្យួរកិច្ចសន្យាការងារត្រឹមត្រូវតាមប្រកាស និងការណែនាំថ្មីៗ របស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ។

៣- **ចំណុចទី៣**

**-ភាគីតំណាងកម្មករនិយោជិត** ទាមទារអោយនិយោជកទទួលយកកម្មករនិយោជិតចំនួន ៧៥នាក់ ចូលធ្វើការវិញ ដោយគិតប្រាក់រំលឹក ចាប់ពីថ្ងៃបញ្ឈប់ រហូតដល់ថ្ងៃចូលធ្វើការ ដោយនិយោជកមិនបានព្យួរកិច្ចសន្យាការងារតាមនិតិវិធីច្បាប់ និងនិយោជកមិនបានគិតប្រាក់រំលឹកស្របតាមនីតិវិធី។

**បញ្ជាក់៖** ចំពោះការទាមទារបន្ថែម ស្នើអោយនិយោជកជួយសំរួលបំពេញឯកសារកម្មករនិយោជិតចំនួន ៣៤នាក់ ដែលពុំទាន់ទទួលបានប្រាក់ឧបត្ថម្ភពីរដ្ឋាភិបាលនៅឡើយ គឺភាគីកម្មករនិយោជិតសុំដកការទាមទារវិញ។

**-ភាគីខាងនិយោជក** ខាងក្រុមហ៊ុនបានទទួលកម្មករនិយោជិតចំនួន ៥៨នាក់ ក្នុងចំណោមកម្មករនិយោជិតចំនួន ៧៦នាក់ ចំណែកកម្មករចំនួន ១៨នាក់ទៀត មិនព្រមចុះកិច្ចសន្យាការងារសាថ្មី ដោយទាមទាររក្សាអតីតភាពការងារចាស់ពីមុន ដូចនេះក្រុមហ៊ុនមិនអាចទទួលយកបានទេ។

បញ្ជាក់៖ ក្នុងចំណោម ១៨នាក់នោះ មានខ្លះត្រឡប់ទៅស្រុកកំណើត និងទាក់ទងតាមទូរសព្ទមិនបាន។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៨៥/២០ ក.ប/ប្រ.ក.រ.ក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ (អាណត្តិទី១៨)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ផេក ធីក (ខេមបូឌា) ខូអិលធីឌី លេខ ០៤០ ម.ក.ប ចុះថ្ងៃសុក្រ ១៤រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២០ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ** ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ** ៖ ថ្ងៃពុធ ១១កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក។

**បញ្ហានីតិវិធី ៖**

នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប បានទទួលពាក្យបណ្តឹងរបស់កម្មករនិយោជិត នៃក្រុមហ៊ុន ផេក ធីក (ខេមបូឌា) ខូ អិលធីឌី ស្តីពីការទាមទារឱ្យក្រុមហ៊ុនដោះស្រាយលក្ខខណ្ឌការងារចំនួន ៣ចំណុច។ បន្ទាប់ពីទទួលពាក្យបណ្តឹងនេះមក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប បានចាត់មន្ត្រីជំនាញឱ្យដោះស្រាយវិវាទការងារនេះ ទៅតាមនីតិវិធីច្បាប់ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ។ ចំណុចមិនសះជា ចំនួន ៣ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ផេក ធីក (ខេមបូឌា) ខូ អិលធីឌី លេខ ០៤០ ម.ក.ប ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២០។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិត

THE ARBITRATION COUNCIL

មកសវនាការ និងផ្សះផ្សា នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ៨ និង ៣០នាទី ព្រឹក។ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទមិនសះជាចំនួន ៣ចំណុចនេះ និងបានផ្សះផ្សាលើចំណុចវិវាទបន្ថែមទៀត ដោយភាគីកម្មករនិយោជិតសម្រេចដកការទាមទារចំនួន ១ចំណុច ចេញពីសំណុំរឿងនេះ គឺចំណុចវិវាទទី២ និងបានព្រមព្រៀងគ្នាលើចំណុចវិវាទទី៣។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាចំណុចវិវាទដែលនៅសល់តែមួយចំណុចប៉ុណ្ណោះ គឺចំណុចវិវាទទី១។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២០ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារភស្តុតាង និងថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២០ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារភស្តុតាង។

ភាគីទាំងពីរបានឯកភាពពន្យារកាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០ ទៅយ៉ាងយូរ ត្រឹមថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០ វិញ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតផ្ទេរសិទ្ធិរបស់លោក Holten Petrus ជានាយកក្រុមហ៊ុន ផេក ធីក (ខេមបូឌា) ខូអិលធីឌី ចុះថ្ងៃចន្ទ ២កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០ គោរពជូន ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសូមផ្ទេរសិទ្ធិជូន លោក A.A.C.CHATURANGA ជាប្រធានគ្រប់គ្រងប្រតិបត្តិការ។

២- លិខិតផ្ទេរសិទ្ធិរបស់លោក Holten Petrus ជានាយកក្រុមហ៊ុន ផេក ធីក (ខេមបូឌា) ខូអិលធីឌី ចុះថ្ងៃសៅរ៍ ៧កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២៧ ខែមិថុនា ឆ្នាំ ២០២០ គោរពជូន ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសូមផ្ទេរសិទ្ធិជូន លោកស្រី ធឹម ថាវី កញ្ញា Sandra D'Amico លោក សយ ធារិទ្ធិ និងលោកស្រី ខ្លឹម សុផាណារី។

៣- សារណាសង្ខេបនៃវិវាទការងារ ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០ របស់ក្រុមហ៊ុន ផេក ធីក (ខេមបូឌា) ខូអិលធីឌី។

៤- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុន ផេក ធីក (ខេមបូឌា) ខូអិលធីឌី លេខ Moc-៩១២០៧៨៧១៣ណ.ចបព ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១២។

៥- ប្រកាសបង្កើតរោងចក្រ លេខ ០១៦ ឧស.កឧ.ប្រក.០១ ចុះថ្ងៃចន្ទ ១៤រោច ខែមុស្ស ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨។

៦- វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ-សិប្បកម្ម ក្រុមហ៊ុន ផេក ធីក (ខេមបូឌា) ខូអិលធីឌី លេខ ០០៨៧ ឧស.កឧ.ប្រក.០១ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨។

៧- លក្ខន្តិកៈក្រុមហ៊ុន ផេក ធីក (ខេមបូឌា) ខូអិលធីឌី បានតម្កល់ទុកលេខ ៣៥៦២/២០១០ ពណ.ចបព ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៥ នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម។

៨- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ផេក ធីក (ខេមបូឌា) ខូអិលធីឌី ចុះទិដ្ឋាការ លេខ ០៥១ មកប ចុះថ្ងៃ ទី០៥ ខែមិថុនា ឆ្នាំ២០១២។

៩- ប័ណ្ណពន្ធប៉ាតង់ក្រុមហ៊ុន ផេក ធីក (ខេមបូឌា) ខូអិលធីឌី លេខ ០០៨២៥ អពដ/សខ/សរ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៤។

១០- លិខិតបញ្ជាក់ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២០ របស់សមាគមន៍កាត់ដេរកម្ពុជា (GMAC)។

១១- លិខិតចុះថ្ងៃចន្ទ ៧កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ របស់ក្រុមហ៊ុន ផេក ធីក (ខេមបូឌា) ខូអិលធីឌី គោរពជូន ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីសេចក្តីបំភ្លឺអំពីប្រាក់បៀវត្សន៍អប្បបរមារបស់ក្រុមហ៊ុន ផេក ធីក (ខេមបូឌា) ខូអិលធីឌី។

១២- របាយការណ៍ស្តីពីប្រាក់បៀវត្សន៍អប្បបរមារបស់ក្រុមហ៊ុន ផេក ធីក (ខេមបូឌា) ខូអិលធីឌី ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០។

១៣- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីអនុវត្តអនុក្រឹត្យលេខ ១០៨ ក្រុមហ៊ុន ផេក ធីក (ខេមបូឌា) ខូអិលធីឌី លេខ ៧៣៧ ស.អ.យ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩។

១៤- វិញ្ញាបនបត្រ បទដ្ឋាន SA៨០០០:២០១៤ លេខចុះបញ្ជីការរបស់វិញ្ញាបនបត្រ ១៧ ១១៤ ១៥៣៥៦៥១ ក្រុមហ៊ុនកាន់វិញ្ញាបនបត្រ ក្រុមហ៊ុន ផេក ធីក (ខេមបូឌា) ខូអិលធីឌី។

១៥- លិខិតលេខ ០០៤ ម.ក.ប ចុះថ្ងៃចន្ទ ១៥រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប ជម្រាបមក លោកនាយកក្រុមហ៊ុន ផេក ធីក (ខេមបូឌា) ខូអិលធីឌី ស្តីពីការឆ្លើយតបសេចក្តីបំភ្លឺអំពីប្រាក់បៀវត្សអប្បបរមារបស់ក្រុមហ៊ុន ផេក ធីក (ខេមបូឌា) ខូអិលធីឌី។

១៦- សេចក្តីណែនាំស្តីពីការបើករំលឹកប្រាក់បំណាច់អតីតភាពការងារដែលមានមុនឆ្នាំ២០១៩ សម្រាប់សហគ្រាសគ្រឹះស្ថានផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើង លេខ ០៥៧/១៩ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃចន្ទ ៨កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩។

១៧- សេចក្តីណែនាំស្តីពីការបើករំលឹកប្រាក់បំណាច់អតីតភាពការងារដែលមានមុនឆ្នាំ២០១៩ សម្រាប់សហគ្រាស គ្រឹះស្ថានក្រៅពីផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើង លេខ ០៤២/១៩ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃសុក្រ ២រោច ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩។

THE ARBITRATION COUNCIL

១៨- របៀបវារៈនៃការប្រជុំអំពីការព្យួរកិច្ចសន្យាការងារ និងការជូនដំណឹងក្រុមហ៊ុនកំពុងកំពុងស្ថិតក្នុងស្ថានភាពលំបាកយ៉ាងធ្ងន់ធ្ងរ ទាក់ទងនិងសេដ្ឋកិច្ចដែលបណ្តាលមកពីការរីករាលដាលនៃជម្ងឺកូវីដ-១៩ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០២០ របស់ក្រុមហ៊ុន ផេក ជីក (ខេមបូឌា) ខូអិលធីឌី។

១៩- កំណត់ហេតុស្តីពីការសាកសួរព័ត៌មានពីតំណាងភាគីនិយោជកនៃក្រុមហ៊ុន ផេក ជីក (ខេមបូឌា) ខូអិលធីឌី ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២០។

២០- លិខិតអញ្ជើញភាគីនិយោជកចូលរួមផ្តល់ព័ត៌មាន លេខ ១១៣ ម.ក.ប ចុះថ្ងៃអង្គារ ១២កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប។

២១- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ផេក ជីក (ខេមបូឌា) ខូអិលធីឌី ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០។

២២- លិខិតអញ្ជើញភាគីនិយោជកចូលផ្សះផ្សាវិវាទការងារ លេខ ១១៥ ម.ក.ប ចុះថ្ងៃសុក្រ ១៥កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២០ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប។

២៣- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលផ្សះផ្សាវិវាទការងារ លេខ ១១៦ ម.ក.ប ចុះថ្ងៃសុក្រ ១៥កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២០ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប។

២៤- កំណត់ហេតុស្តីពីការសាកសួរព័ត៌មានពីតំណាងភាគីនិយោជកនៃក្រុមហ៊ុន ផេក ជីក (ខេមបូឌា) ខូអិលធីឌី ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២០។

២៥- លិខិតចុះថ្ងៃព្រហស្បតិ៍ ១០កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០២ ខែមេសា ឆ្នាំ២០២០ របស់ក្រុមហ៊ុន ផេក ជីក (ខេមបូឌា) ខូអិលធីឌី គោរពជូន ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប ស្តីពីសំណើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ៤៨៦នាក់ រយៈពេល ៦សប្តាហ៍។

២៦- លិខិតបញ្ជាក់ និងព្រមព្រៀងពីតំណាងបុគ្គលិក និងសហជីព ចុះថ្ងៃព្រហស្បតិ៍ ១០កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០២ ខែមេសា ឆ្នាំ២០២០។

២៧- ការព្យួរកិច្ចសន្យារបស់ក្រុមហ៊ុន ផេក ជីក (ខេមបូឌា) ខូអិលធីឌី ជូនចំពោះ រៀន ចរិយា។

២៨- កំណត់ហេតុស្តីពីការសាកសួរព័ត៌មានពីតំណាងភាគីនិយោជកនៃក្រុមហ៊ុន ផេក ជីក (ខេមបូឌា) ខូអិលធីឌី ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២០។

២៩- លិខិតធានាអះអាង ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២០។

៣០- លិខិតបញ្ជាក់ និងព្រមព្រៀងពីតំណាងបុគ្គលិក និងសហជីព ចុះថ្ងៃពុធ ៨កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២០។

៣១- សៀវភៅសម្រាប់កត់ត្រាឯកសារចេញចូលរបស់ក្រុមហ៊ុន ផេក ជីក (ខេមបូឌា) ខូអិលធីឌី។

THE ARBITRATION COUNCIL

៣២- លិខិតលេខ ០៩៨ មកប ចុះថ្ងៃសៅរ៍ ៣រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២០ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប ជម្រាបមក លោកនាយកក្រុមហ៊ុន ផេក ជីក ខេមបូឌា ខូអិលធីឌី (វិស័យផលិតផលធ្វើដំណើរ និងកាបូប) ស្តីពីការអនុញ្ញាតព្យួរកិច្ចសន្យាការងារកម្មករនិយោជិត។

៣៣- កំណត់ហេតុនៃការប្រជុំជូនដំណឹងអំពីការបញ្ចប់កិច្ចសន្យាការងារបុគ្គលិកវេនB និងការជូនដំណឹងដែលក្រុមហ៊ុនកំពុងស្ថិតក្នុងស្ថានភាពលំបាកយ៉ាងធ្ងន់ធ្ងរ ទាក់ទងនិងសេដ្ឋកិច្ចដែលបណ្តាលមកពីការរីករាលដាលនៃជំងឺកូវីដ-១៩ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០។

៣៤- កំណត់ហេតុនៃការប្រជុំជាមួយសហជីពឯករាជ្យសាមគ្គីអំពីការពិភាក្សាលើវិវាទការងាររួម របស់កម្មករនិយោជិត (ចំពោះបុគ្គលិកវេនB នៃការបញ្ចប់កិច្ចសន្យា) ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០។

៣៥- ការប្រជុំជូនដំណឹងបុគ្គលិកដែលត្រូវបញ្ចប់កិច្ចសន្យាការងារ បុគ្គលិកនៅវេនB ។

៣៦- លិខិតជូនដំណឹងជាផ្លូវការនៃការបញ្ចប់កិច្ចសន្យា ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០ របស់ក្រុមហ៊ុន ផេក ជីក ខេមបូឌា ខូអិលធីឌី ជូនចំពោះ រុន ស្រីពៅ។

៣៧- តារាងប្រាក់ខែលំអិតសម្រាប់បុគ្គលិកវេនទី២ ប្រាក់ខែចុងក្រោយ។

៣៨- តារាងប្រាក់អតីតភាពការងារក្នុងឆ្នាំ២០២០។

៣៩- តារាងប្រាក់រំលឹកអតីតភាពការងារមុនឆ្នាំ២០១៩។

៤០- តារាងឈ្មោះបុគ្គលិកវេន B ។

៤១- លិខិតរបស់ប្រធានផ្នែកធនធានមនុស្ស គោរពជូន លោកប្រធានក្រុមអាជ្ញាកណ្តាល ស្តីពីសារណាការពាររបស់ក្រុមហ៊ុន ផេក ជីក ខេមបូឌា ខូអិលធីឌី។

៤២- លិខិតលេខ ០០៣/២០ ម.ក.ប ចុះថ្ងៃសុក្រ ៨រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០ របស់ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប ជម្រាបមក លោកប្រធានសហជីពឯករាជ្យសាមគ្គី និយោជិតនៃរោងចក្រ ផេក ជីក ស្តីពីការស្នើសុំទទួលស្គាល់ថ្នាក់ដឹកនាំសហជីពថ្មី។

៤៣- ញត្តិគាំទ្ររបស់កម្មករនិយោជិតនៅរោងចក្រ ផេកជីក ចុះថ្ងៃសៅរ៍ ១២កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២០។

៤៤- លិខិតស្នើសុំ ចុះថ្ងៃអង្គារ ១៤រោច ខែចេត្រ ឆ្នាំជូត ទោស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី២១ ខែមេសា ឆ្នាំ២០២០ របស់ថ្នាក់ដឹកនាំសហជីពឯករាជ្យសាមគ្គីនិយោជិតនៃរោងចក្រ ផេកជីក & ប្រតិភូបុគ្គលិកប្រចាំរោងចក្រ ផេកជីក គោរពជូន លោកអគ្គនាយកនៃក្រុមហ៊ុន ផេកជីក ស្តីពី ស្នើសុំជួបពិភាក្សាលើវិវាទការងាររួម រវាងកម្មករនិយោជិតនៃក្រុមហ៊ុន ផេកជីក និងនិយោជកនៃក្រុមហ៊ុន ផេកជីក។

៤៥- ឯកសាររូបភាព។

៤៦- ឯកសារជាភាសាបរទេស។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១- លិខិតតំណាងដោយអាណត្តិរបស់លោកមេធាវី ឈេន សំបូរ គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីតំណាងដោយអាណត្តិឱ្យអាណត្តិទាយក ឈ្មោះ ម៉េត រ៉ាត់ ឈ្មោះ គ្រឿន ស្រីនិច ឈ្មោះ យ៉ាន់ វណ្ណា ឈ្មោះ ចាន់ វន្នី ឈ្មោះ សោម គីមហុង និងឈ្មោះ រឹង រ៉ង ក្នុងសំណុំរឿងលេខ ០៣៨/២០ របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃពុធ ១១កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ពស ២៥៦៤ ត្រូវនឹងថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០។

២- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិរបស់អាណត្តិទាយកឈ្មោះ ម៉េត រ៉ាត់ ឈ្មោះ គ្រឿន ស្រីនិច ឈ្មោះ យ៉ាន់ វណ្ណា ឈ្មោះ ចាន់ វន្នី ឈ្មោះ សោម គីមហុង និងឈ្មោះ រឹង រ៉ង ប្រគល់សិទ្ធិជូនលោកមេធាវី ឈេន សំបូរ ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២០។

៣- លិខិតលេខ ០០៣/២០ ម.ក.ប ចុះថ្ងៃសុក្រ ៨រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០ របស់ប្រធានមន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប ជម្រាបមក លោកប្រធានសហជីពឯករាជ្យសាមគ្គីនិយោជិតនៃរោងចក្រ ផេកជីក ស្តីពីការស្នើសុំទទួលស្គាល់ថ្នាក់ដឹកនាំសហជីពថ្មី។

៤- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ផេក ជីក (ខេមបូឌា) ខូអិលធីឌី លេខ ០០០៤/០៦/២០ មកប ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប។

៥- កិច្ចសន្យាការងាររវាងក្រុមហ៊ុន ផេក ជីក ខេមបូឌា ខូអិលធីឌី និងកម្មករនិយោជិត។

៦- សេចក្តីថ្លែងការណ៍ពីការអនុវត្តគោលការណ៍សុច្ចរិតភាព និងការប្រឆាំងអំពើពុករលួយរបស់បុគ្គលិករបស់ក្រុមហ៊ុន ផេក ជីក ខេមបូឌា ខូអិលធីឌី។

៧- កំណត់ហេតុស្តីពីការសាកសួរព័ត៌មានពីតំណាងភាគីកម្មករនិយោជិតនៃក្រុមហ៊ុន ផេក ជីក (ខេមបូឌា) ខូអិលធីឌី ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២០។

៨- កំណត់ហេតុស្តីពីកិច្ចប្រជុំបង្កើតសហជីពឯករាជ្យសាមគ្គីនិយោជិតនៃរោងចក្រ ផេកជីក ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៩។

៩- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ផេក ជីក (ខេមបូឌា) ខូអិលធីឌី ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០។

១០- ពាក្យបណ្តឹងរបស់កម្មករនិយោជិតនៃក្រុមហ៊ុន ផេក ជីក (ខេមបូឌា) ខូអិលធីឌី ចុះថ្ងៃសុក្រ ៩រោច ខែពិសាខ ឆ្នាំជូត ទោស័ក ពស ២៥៦៤ ត្រូវនឹងថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០ គោរពជូនលោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប។

១១- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមផ្តល់ព័ត៌មាន លេខ ១០៤ មកប ចុះថ្ងៃព្រហស្បតិ៍ ១៥រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២០ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប។

THE ARBITRATION COUNCIL

១២- កំណត់ហេតុស្តីពីការសាកសួរព័ត៌មានពីតំណាងភាគីកម្មករនិយោជិតនៃក្រុមហ៊ុន ផេក ជីក (ខេមបូឌា) ខូអិលធីឌី ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២០។

១៣- កំណត់ហេតុស្តីពីការសាកសួរព័ត៌មានពីតំណាងភាគីកម្មករនិយោជិតនៃក្រុមហ៊ុន ផេក ជីក (ខេមបូឌា) ខូអិលធីឌី ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០។

១៤- កំណត់ហេតុស្តីពីការសាកសួរព័ត៌មានពីតំណាងភាគីកម្មករនិយោជិតនៃក្រុមហ៊ុន ផេក ជីក (ខេមបូឌា) ខូអិលធីឌី ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០២០។

១៥- លិខិតអញ្ជើញភាគីនិយោជកចូលផ្សះផ្សាវិវាទការងារ លេខ ១១៥ ម.ក.ប ចុះថ្ងៃសុក្រ ១៥កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២០ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប។

១៦- លិខិតលេខ ០៩៨ មកប ចុះថ្ងៃសៅរ៍ ៣រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២០ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប ជម្រាបមក លោកនាយកក្រុមហ៊ុន ផេក ជីក ខេមបូឌា ខូអិលធីឌី (វិស័យផលិតផលធ្វើដំណើរ និងកាបូប) ស្តីពីការអនុញ្ញាតព្យួរកិច្ចសន្យាការងារកម្មករនិយោជិត។

១៧- កំណត់ហេតុស្តីពីការសាកសួរព័ត៌មានពីតំណាងភាគីកម្មករនិយោជិតនៃក្រុមហ៊ុន ផេក ជីក (ខេមបូឌា) ខូអិលធីឌី ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០២០។

១៨- លក្ខន្តិកៈនៃសហជីពឯករាជ្យសាមគ្គីភាពនិយោជិតនៃរោងចក្រ ផេកជីក បានចុះបញ្ជីលើលក្ខន្តិកៈថ្មីនៃបញ្ជិកាលេខ ១១៧១៨០០១៥ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៨។

១៩- បញ្ជីឈ្មោះអ្នកចូលរួមប្រជុំការព្យួរកិច្ចសន្យាការងារក្រុមហ៊ុន ផេក ជីក (ខេមបូឌា) ខូអិលធីឌី ចុះថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២០។

២០- លិខិតលេខ ១៧៣ មកប ចុះថ្ងៃចន្ទ ១១កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប ជម្រាបមក លោកនាយកក្រុមហ៊ុន ផេក ជីក ខេមបូឌា ខូអិលធីឌី (វិស័យផលិតផលធ្វើដំណើរ និងកាបូប) ស្តីពីការអនុញ្ញាតព្យួរកិច្ចសន្យាការងារកម្មករនិយោជិត។

២១- បញ្ជីរាយនាមកម្មករនិយោជិតដែលស្នើសុំព្យួរកិច្ចសន្យាការងារក្រុមហ៊ុន ផេក ជីក ខេមបូឌា ខូអិលធីឌី (សកម្មភាពអាជីវកម្មផលិតផលធ្វើដំណើរ និងកាបូប) រយៈពេលព្យួរកិច្ចសន្យាការងារ ៦១ថ្ងៃ ចាប់ពីថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២០ ដល់ថ្ងៃទី៦ ខែសីហា ឆ្នាំ២០២០។

២២- បញ្ជីរាយនាមកម្មករនិយោជិតដែលស្នើសុំព្យួរកិច្ចសន្យាការងារក្រុមហ៊ុន ផេក ជីក ខេមបូឌា ខូអិលធីឌី (ផលិតក្រណាត់ជូតវ៉ែនតា កាបូប និងសំភារៈប្រណិតបន្ទាប់បន្សំ) រយៈពេលព្យួរកិច្ចសន្យាការងារ ២៩ថ្ងៃ ចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២០ ដល់ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០។

២៣- វិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈសហជីពឯករាជ្យសាមគ្គី និយោជិតនៃរោងចក្រ ផេក ជីក លេខ ០០៦ ម.ក.ប ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៨។

THE ARBITRATION COUNCIL

២៤- ការកែប្រែកិច្ចសន្យា កាលបរិច្ឆេទ ៣១ ខែមីនា ឆ្នាំ២០២០ ឈ្មោះ សំ ឡូន តំណែង ជាងដេរភ្ជាប់ ក្រុមហ៊ុន ផេក ធីក ខេមបូឌា ខូអិលធីឌី។

២៥- ញត្តិគាំទ្ររបស់កម្មករនិយោជិតនៃក្រុមហ៊ុន ផេក ធីក ខេមបូឌា ខូអិលធីឌី ចុះថ្ងៃសៅរ៍ ១២កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ពស ២៥៦៣ ត្រូវនឹងថ្ងៃទី៤ ខែមេសា ឆ្នាំ២០២០។

២៦- សេចក្តីជូនដំណឹងស្តីពីការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតវិស័យកាត់ដេរ និង ទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋា-ភិបាល (លើកទី៦) ចុះថ្ងៃអង្គារ ១១រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០២០។

២៧- ឧបសម្ព័ន្ធនៃសេចក្តីជូនដំណឹង ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០ ស្តីពីបញ្ជីឈ្មោះរោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍ចំនួន ៩១ ដែលទទួលបានប្រាក់ឧបត្ថម្ភ របស់រាជរដ្ឋាភិបាល។

២៨- បង្កាន់ដៃបើកប្រាក់ឈ្នួលខែមេសា ឧសភា និងខែមិថុនា ឆ្នាំ២០២០។

២៩- សារណាការពារ ចុះថ្ងៃចន្ទ ១រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២០។

៣០- ឯកសាររូបភាព។

៣១- ឯកសារជាភាសាបរទេស។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ផេក ធីក (ខេមបូឌា) ខូអិលធីឌី លេខ ០៤០ ម.ក.ប ចុះថ្ងៃសុក្រ ១៤រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២០។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ផេក ធីក (ខេមបូឌា) ខូអិលធីឌី ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០២០។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ផេក ធីក (ខេមបូឌា) ខូអិលធីឌី លេខ ០០០៤/០៦/២០ មកប ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ២៣១ កប/អក/វក/លកអ. ចុះថ្ងៃពុធ ៤កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ២៣២ កប/អក/វក/លកអ. ចុះថ្ងៃពុធ ៤កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០។

THE ARBITRATION COUNCIL

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

- ក្រុមហ៊ុន ផេក ធីក (ខេមបូឌា) ខូ អិលធីឌី គឺជាក្រុមហ៊ុនមានសកម្មភាពចម្បងផ្នែកដេរក្រណាត់ជូតវែនតា និងមានជួលកម្មករនិយោជិតសរុបចំនួន ៥០០នាក់។ *(យោងតាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ផេក ធីក (ខេមបូឌា) ខូ អិលធីឌី)*

**ចំណុចវិវាទទី ១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកសងប្រាក់រំលឹកអតីតភាពការងារមុនឆ្នាំ២០១៩ ដល់កម្មករនិយោជិតតាមច្បាប់**

- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារ ឱ្យនិយោជកបើកប្រាក់រំលឹកអតីតភាពការងារមុនឆ្នាំ២០១៩ ជូនកម្មករនិយោជិត ស្របតាមមាត្រា ៨៩ថ្មី, ប្រកាសលេខ ៤៤៣ និងសេចក្តីណែនាំលេខ ០៥៧។
- ភាគីទាំងពីរទទួលស្គាល់ថា ៖
    - ក្រុមហ៊ុននេះ មានសកម្មភាពអាជីវកម្មផ្នែកកាត់ដេរក្រណាត់ជូតវែនតា និងកាបូប។
    - និយោជកមិនទាន់បានអនុវត្តបើកប្រាក់រំលឹកអតីតភាពការងារមុនឆ្នាំ២០១៩ ជូនកម្មករនិយោជិតទេ ដោយនិយោជកពន្យារការអនុវត្តនេះរហូតដល់ឆ្នាំ២០២១ តាមសេចក្តីណែនាំលេខ ០៤២ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។
    - នៅក្នុងខែមករា ឆ្នាំ២០២០ បន្ទាប់ពីចុះធ្វើអធិការកិច្ច អធិការការងារនៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប បានសម្រេចឱ្យនិយោជកអនុវត្តប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង សម្រាប់ឆ្នាំ២០២០។
    - នៅក្នុងខែមីនា ឆ្នាំ២០២០ និយោជកបានដាក់លិខិតទៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប ដើម្បីសុំការបកស្រាយពីលោកប្រធានមន្ទីរអំពីការដាក់កំហិតដោយអធិការការងារឱ្យនិយោជកអនុវត្តប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង។ ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប បានបញ្ជាក់ពីភាពត្រឹមត្រូវនៃការសម្រេចរបស់អធិការការងារ និងបានគូសបញ្ជាក់ឱ្យនិយោជកដាក់សំណើសុំបកស្រាយទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបន្តទៀត ក្នុងករណីនៅតែមានភាពមិនច្បាស់លាស់។ និយោជកមិនយល់ស្របនឹងការសម្រេចនេះទេ ដោយគាត់បានដាក់លិខិតជំទាស់ទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។
    - មកដល់ថ្ងៃសវនាការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មិនទាន់បានឆ្លើយតបនឹងសំណើសុំបកស្រាយរបស់និយោជកទាក់ទងនឹងប្រភេទអាជីវកម្មរបស់ក្រុមហ៊ុនថាស្ថិតនៅក្នុងវិស័យអ្វីនោះទេ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា ៖
    - ក្រុមហ៊ុននេះ មានសកម្មភាពអាជីវកម្មក្នុងវិស័យកាត់ដេរ ទោះក្រុមហ៊ុននេះកាត់ដេរក្រណាត់ជូតវែនតា និងកាបូប ដែលមិនមែនជាសម្លៀកបំពាក់ក៏ដោយ។

- ០ យោងតាមសេចក្តីជូនដំណឹង ស្តីពីការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារ ស្របតាមស្មារតីនៃកញ្ចប់វិធានការរាជរដ្ឋាភិបាល (លើកទី៦) ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចាត់ប្រភេទក្រុមហ៊ុន ផេក ធីក នៅក្នុងលេខរៀងទី៥៦ ថាជាក្រុមហ៊ុនក្នុងវិស័យកាត់ដេរ។
- ០ កម្មករនិយោជិតយល់ឃើញថា ក្រុមហ៊ុន ផេក ធីក គឺស្ថិតនៅក្នុងវិស័យវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង។ ហេតុនេះ សេចក្តីណែនាំលេខ ០៤២ មិនមានវិសាលភាពអនុវត្តលើក្រុមហ៊ុននេះទេ ពីព្រោះសេចក្តីណែនាំនេះ គឺសម្រាប់អនុវត្តតែចំពោះសហគ្រាស ឬគ្រឹះស្ថានក្រៅពីវិស័យវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងតែប៉ុណ្ណោះ។

- ភាគីនិយោជកមិនអាចផ្តល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតបានទេ ដោយមូលហេតុថា ៖
  - ០ យោងតាមលក្ខន្តិកៈក្រុមហ៊ុន ផេក ធីក (ខេមបូឌា) ខូ អិលធីឌី និងបណ្ណប៉ាតង់ សកម្មភាពចម្បងរបស់ក្រុមហ៊ុននេះ គឺផលិតក្រណាត់ជូតវ៉ែនតា ពីក្រណាត់ម៉ៃក្រូហ្វៃប៊ើរ មិនមែនកាត់ដេរសម្លៀកបំពាក់នោះទេ។
  - ០ ដោយសារតែក្រុមហ៊ុន ផេក ធីក មិនមែនជារោងចក្រកាត់ដេរសម្លៀកបំពាក់ ទើបក្រុមហ៊ុននេះចុះបញ្ជីជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម ហើយត្រូវបានទទួលស្គាល់ថាជាសិប្បកម្ម។
  - ០ សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) ចាត់ទុកក្រុមហ៊ុននេះជាសមាជិកសហការី (Associate Member) មិនមែននៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ទេ។
  - ០ យោងតាមសេចក្តីណែនាំលេខ ០៤២ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និយោជកអាចពន្យារការបើកប្រាក់បំណាច់អតីតភាពការងារទៅឆ្នាំ២០២១ ពីព្រោះក្រុមហ៊ុន ផេក ធីក គឺនៅក្រៅវិស័យវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង។

- ភាគីនិយោជកបានដាក់ឯកសារជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណា ដូចខាងក្រោម ៖
  - ០ យោងតាមបណ្ណប៉ាតង់ចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ ០០៨២៥ អពដ/សខ/សរ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៤ សកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុន ផេក ធីក គឺសិប្បកម្មកែច្នៃថង់ក្រណាត់ជូតវ៉ែនតា និងនាឡិកា។
  - ០ យោងតាមវិញ្ញាបនបត្រចេញដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម លេខ ០០៨៧ឧ.ស.ក.ឧ.វ.ប.០១ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨ ក្រុមហ៊ុន ផេក ធីក ត្រូវបានអនុញ្ញាតឱ្យដំណើរការរោងចក្រផលិតថង់ក្រណាត់ដាក់វ៉ែនតា ក្រណាត់ជូតនាឡិកា កាបូប និងសម្ភារៈប្រើប្រាស់ពីកំទេចក្រណាត់។
  - ០ យោងតាមប្រការ ១ នៃប្រកាសបង្កើតរោងចក្រចេញដោយទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៨ ក្រុមហ៊ុន ផេក ធីក ត្រូវបានអនុញ្ញាតឱ្យបង្កើតរោងចក្រផលិតថង់ក្រណាត់ដាក់វ៉ែនតា, ក្រណាត់ជូតនាឡិកា, សម្ភារៈប្រើប្រាស់ពីកំទេចក្រណាត់ (ដែលមានលេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ១៣៩៩) និងកាបូប (ដែលមានលេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ១៥១២)។
  - ០ លិខិតឆ្លើយចេញដោយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប ឆ្លើយតបសេចក្តីបំភ្លឺអំពីប្រាក់បៀវត្សអប្បបរមារបស់ក្រុមហ៊ុន ផេក ធីក (ខេមបូឌា) ខូ អិលធីឌី ចុះថ្ងៃទី២៣

THE ARBITRATION COUNCIL

ខែមីនា ឆ្នាំ២០២០ ដែលលោកប្រធានមន្ទីរបានបញ្ជាក់ថា ការដាក់កំហិតរបស់អធិការការងារឱ្យនិយោជកអនុវត្ត គឺត្រឹមត្រូវស្របតាមស្មារតីនៃប្រកាសលេខ ៣៨៩/១៩ ក.ប/ប្រ.ក.ល.ខ ចុះថ្ងៃទី២០ខែកញ្ញា ឆ្នាំ២០១៩ ស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងសម្រាប់ឆ្នាំ២០២០ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

- ភាគីកម្មករនិយោជិតបានដាក់ឯកសារ និងរូបភាពជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណា ដូចខាងក្រោម ៖
  - យោងតាមឧបសម្ព័ន្ធនៃសេចក្តីជូនដំណឹង ស្តីពីការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារ ស្របតាមស្មារតីនៃកិច្ចប្រជុំពិភាក្សារបស់រាជរដ្ឋាភិបាល (លើកទី៦) ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ ក្រុមហ៊ុន ផេក ធីក គឺនៅក្នុងវិស័យកាត់ដេរ នៅក្នុងលេខរៀងទី៥៦។
  - រូបភាពដែលបង្ហាញអំពីសង្វាក់ផលិតកម្ម និងសកម្មភាពកាត់ដេរក្រណាត់របស់កម្មករនិយោជិតដែលពាក់អាវមានស្លាកសញ្ញាក្រុមហ៊ុន ផេក ធីក។

## **ហេតុផលនៃសេចក្តីសម្រេច ៖**

**ចំណុចវិវាទទី១ ៖ ភាគីកម្មករនិយោជិតទាមទារ ឱ្យនិយោជកបើកប្រាក់រំលឹកអតីតភាពការងារមុនឆ្នាំ២០១៩ ជូនកម្មករនិយោជិត ស្របតាមមាត្រា ៨៩ថ្មី, ប្រកាសលេខ ៤៤៣ និងសេចក្តីណែនាំលេខ ០៥៧**

នៅក្នុងសំណុំរឿងនេះ និយោជកមិនទាន់បានបើកប្រាក់រំលឹកអតីតភាពការងារមុនឆ្នាំ២០១៩ ជូនកម្មករនិយោជិតនោះទេ ដោយនិយោជកលើកមូលហេតុថា ក្រុមហ៊ុន ផេក ធីក គឺនៅក្រៅវិស័យវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង ហេតុនេះ និយោជកអនុវត្តតាមសេចក្តីណែនាំលេខ ០៤២ របស់ក្រសួងការងារ និងបណ្តុះ-បណ្តាលវិជ្ជាជីវៈ។

ករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចអនុវត្តបើកប្រាក់រំលឹកអតីតភាពការងារមុនឆ្នាំ២០១៩ ជូនកម្មករនិយោជិត ស្របតាមមាត្រា ៨៩ថ្មី, ប្រកាស ៤៤៣ និងសេចក្តីណែនាំលេខ ០៥៧ ដែរ ឬទេ?

មាត្រាពីរ នៃច្បាប់ស្តីពីវិសោធនកម្ម មាត្រា ៨៧ ចំណងជើងចំណុច "គ" ផ្នែកទី៣ នៃជំពូកទី៤ មាត្រា ៨៩ មាត្រា ៩០ មាត្រា ៩១ មាត្រា ៩៤ មាត្រា ១១០ មាត្រា ១២០ និងមាត្រា ១២២ នៃច្បាប់ស្តីពីការងារដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ចស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលចូលជាធរមាន ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨ (តទៅនេះហៅថា មាត្រា ពីរ នៃច្បាប់ស្តីពីការងារ) ចែងថា ៖

*"ការគណនា និងទូទាត់អតីតភាពការងាររបស់កម្មករនិយោជិតដែលបានបំពេញការងារមុនច្បាប់នេះចូលជាធរមាន ត្រូវអនុវត្តតាមបែបបទដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ"។*

ប្រការ៣ នៃប្រកាសលេខ ៤៤៣ ក.ប ប្រ.ក.ខ.ល ស្តីពីការទូទាត់ប្រាក់បំណាច់អតីតភាពការងារ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ ចែងថា ៖

*"ការបើករំលឹកប្រាក់បំណាច់អតីតភាពការងារមុនឆ្នាំ២០១៩ របស់កម្មករនិយោជិត ដែលបាននឹងកំពុងបម្រើការនៅតាមសហគ្រាស គ្រឹះស្ថាន ត្រូវអនុវត្តតាមបែបបទដូចខាងក្រោម៖*

*១-ចំពោះសហគ្រាស គ្រឹះស្ថានផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង និយោជកត្រូវបើករំលឹកចំនួន ៣០(សាមសិប)ថ្ងៃ នៃប្រាក់បំណាច់អតីតភាពការងារសរុប រៀងរាល់១(មួយ)ឆ្នាំម្តង ដោយៈ*

- *ចំនួន ១៥(ដប់ប្រាំ)ថ្ងៃ នៅក្នុងខែមិថុនា នៃឆ្នាំនីមួយៗ និង*
- *ចំនួន ១៥(ដប់ប្រាំ)ថ្ងៃ នៅក្នុងខែធ្នូ នៃឆ្នាំនីមួយៗ...*"។

យោងតាមសេចក្តីណែនាំលេខ ០៥៧/១៩ ក.ប/ស.ណ.ន.ខ.ល ស្តីពីការបើករំលឹកប្រាក់បំណាច់អតីតភាពការងារដែលមានមុនឆ្នាំ២០១៩ សម្រាប់សហគ្រាស គ្រឹះស្ថានផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ ចែងថា ៖

*"ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនម្ចាស់ ឬនាយកសហគ្រាសគ្រឹះស្ថានអង្គការវិជ្ជាជីវៈ និងកម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងទាំងអស់ ជ្រាបថា ដើម្បីអនុវត្តប្រកាសលេខ ៤៤៣ ក.ប/ប្រ.ក.ខ.ល ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការទូទាត់ប្រាក់បំណាច់អតីតភាពការងារ ប្រកបដោយប្រសិទ្ធភាពខ្ពស់ និងធានានាសុខដុមរមនាក្នុងទំនាក់ទំនងវិជ្ជាជីវៈ សូមលោក លោកស្រី ជាម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន អង្គការវិជ្ជាជីវៈ និងកម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងត្រូវអនុវត្តតាមសេចក្តីណែនាំ ដូចខាងក្រោមៈ"*

*III - របៀបបើករំលឹកប្រាក់បំណាច់អតីតភាពការងារ*

- *និយោជកត្រូវបើករំលឹកប្រាក់បំណាច់អតីតភាពការងារជូនកម្មករនិយោជិត២ដងក្នុង១ឆ្នាំ ដែលក្នុងម្តងៗស្មើនឹងប្រាក់ឈ្នួលសុទ្ធសាធគិតជាមធ្យមចំនួន ១៥ថ្ងៃ គឺចំនួន ១៥ថ្ងៃ នៅពេលបើកប្រាក់ឈ្នួលលើកទី២ សម្រាប់ខែមិថុនា និងចំនួន ១៥ថ្ងៃទៀត នៅពេលបើកប្រាក់ឈ្នួលលើកទី២ សម្រាប់ខែធ្នូ នៃឆ្នាំនីមួយៗ។ ការបើករំលឹកនេះ និយោជកត្រូវផ្តល់ឱ្យកម្មករនិយោជិតទៅតាមអតីតភាពការងារជាក់ស្តែងរបស់កម្មករនិយោជិតម្នាក់ៗ ពោលគឺចាប់ផ្តើមពីឆ្នាំ២០០៨ រៀងមក ...*

*VI - គោលការណ៍រួម*

*...៦- ប្រាក់រំលឹកអតីតភាពការងារមុនឆ្នាំ២០១៩នេះ ត្រូវបើកជាមួយនឹងប្រាក់ឈ្នួល ដែលកម្មករនិយោជិតត្រូវទទួលលើកទី២ សម្រាប់ខែមិថុនា និងខែធ្នូ។ ដូច្នេះ នៅពេលបើកប្រាក់ឈ្នួលលើកទី២ សម្រាប់ខែមិថុនា និងខែធ្នូ នីមួយៗ កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង ដែលមានអតីតភាពការងារមុនឆ្នាំ២០១៩ ត្រូវទទួលបានប្រាក់ឈ្នួលលើកទី២ សម្រាប់ខែមិថុនា ឬខែធ្នូផង ប្រាក់បំណាច់អតីតភាពការងារថ្មីក្នុងឆមាសនីមួយៗ ចំនួន ៧,៥ថ្ងៃផង និងប្រាក់រំលឹកអតីតភាពការងារមុនឆ្នាំ២០១៩ផង ប្រសិនជាមាន*"។

យោងតាមមាត្រា ពីរ នៃច្បាប់ស្តីពីវិសោធនកម្មការងារ, ប្រការ ៣ នៃប្រកាសលេខ ៤៤៣ និងសេចក្តីណែនាំលេខ ០៥៧/១៩ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង ដែលមានអតីតភាពការងារមុនឆ្នាំ២០១៩ ត្រូវទទួលបានប្រាក់រំលឹកអតីតភាពការងារមុនឆ្នាំ២០១៩ ចំនួន ៣០ថ្ងៃ ក្នុងមួយឆ្នាំ ដែលត្រូវបើកនៅរៀងរាល់ពេលបើកប្រាក់បំណាច់អតីតភាពការងារនៅខែមិថុនា និងខែធ្នូ នៃឆ្នាំនីមួយៗ។ សុរបមក សេចក្តីណែនាំលេខ ០៥៧/១៩ ខាងលើនេះ គឺអនុវត្តសម្រាប់សហគ្រាស គ្រឹះស្ថានផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើក្រុមហ៊ុន ផេក ជីក ស្ថិតនៅក្នុងវិស័យវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងដែរ ឬទេ?

យោងតាមប្រការ ១ នៃប្រកាសបង្កើតរោងចក្រចេញ ដោយទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៨ ក្រុមហ៊ុន ផេក ធីក ត្រូវបានអនុញ្ញាតឱ្យបង្កើតរោងចក្រផលិតថង់ក្រណាត់ដាក់វ៉ែនតា, ក្រណាត់ជូតនាឡិកា, សម្ភារៈប្រើប្រាស់ពីកំទេចក្រណាត់ (ដែលមានលេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ១៣៩៩) និងកាបូប (ដែលមានលេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ១៥១២)។

លើសពីនេះ យោងតាមវិញ្ញាបនបត្រចេញដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម លេខ ០០៨៧ឧ.ស.ក.ឧ.រ.ប.០១ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨ ក្រុមហ៊ុន ផេក ធីក ត្រូវបានអនុញ្ញាតឱ្យដំណើរការរោងចក្រផលិតថង់ក្រណាត់ដាក់វ៉ែនតា ក្រណាត់ជូននាឡិកា កាបូប និងសម្ភារៈប្រើប្រាស់ពីកំទេចក្រណាត់។

យោងតាមប្រកាសបើករោងចក្រ ផេក ធីក និងវិញ្ញាបនបត្ររបស់ក្រុមហ៊ុនខាងលើនេះ និងយោងតាមអង្គហេតុ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ក្រុមហ៊ុន ផេក ធីក មានសកម្មភាពចម្បងកាត់ដេរក្រណាត់ជូតវ៉ែនតា និងកាបូប ពីព្រោះសង្វាក់ផលិតកម្មរបស់ក្រុមហ៊ុន គឺឆ្លងកាត់សកម្មភាពកាត់ និងដេរ ដើម្បីផលិតក្រណាត់ជូតវ៉ែនតា និងកាបូប ហើយវិស័យកាត់ដេរ ដែលមានកំណត់នៅក្នុងសេចក្តីណែនាំលេខ ០៥៧/១៩ ខាងលើ គឺមិនមែនសំដៅទៅលើការកាត់ដេរសម្លៀកបំពាក់តែមួយមុខនោះទេ ពោលគឺឱ្យតែសង្វាក់ផលិតកម្មនៅក្នុងក្រុមហ៊ុនមានសកម្មភាពកាត់ និងដេរ គឺត្រូវបានចាត់ទុកថា នៅក្នុងវិស័យកាត់ដេរ។ ជាងនេះទៀត អធិការការងារខេត្តសៀមរាប ក៏បានចាប់បង្ខំឱ្យក្រុមហ៊ុននេះឱ្យអនុវត្តលក្ខខណ្ឌការងារពាក់ព័ន្ធនឹងការផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិតស្របតាមវិស័យវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងផងដែរ។ មិនតែប៉ុណ្ណោះ យោងតាមលិខិតព្យួរការងារដែលចេញដោយក្រសួងការងារ ក៏បានដាក់ក្រុមហ៊ុននេះនៅក្រោមវិស័យកាត់ដេរផងដែរ។ តាមរយៈការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ក្រុមហ៊ុន ផេក ធីក គឺស្ថិតនៅក្នុងវិស័យវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង។ ដូចនេះ និយោជកត្រូវអនុវត្តការបើកប្រាក់រំលឹកអតីតភាពការងារមុនឆ្នាំ២០១៩ ស្របតាមសេចក្តីណែនាំលេខ ០៥៧/១៩ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បង្គាប់ឱ្យនិយោជកអនុវត្តការបើកប្រាក់រំលឹកអតីតភាពការងារមុនឆ្នាំ២០១៩ ស្របតាមសេចក្តីណែនាំលេខ ០៥៧/១៩ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី១ ៖**

- បង្គាប់ឱ្យនិយោជកអនុវត្តការបើកប្រាក់រំលឹកអតីតភាពការងារមុនឆ្នាំ២០១៩ ស្របតាមសេចក្តីណែនាំលេខ ០៥៧/១៩ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ ចំនួន ០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងរយៈពេលនេះទេ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **អ៊ឹង សុទ្ធី**

ហត្ថលេខា ៖ ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **លីវ សុវណ្ណា**

ហត្ថលេខា ៖------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ម៉ែន ប៊ុនឈា**

ហត្ថលេខា ៖ ------------------------------